លេខ ២៩ ចេញផ្សាយថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែតុលា ឆ្នាំ២០២៣

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨"

នាព្រឹកថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨" នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងដើម្បីផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ ឱ្យបានទូលំទូលាយ ក្នុងស្មារតីជំរុញការអនុវត្ត និងបន្តជំរុញការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា ដោយមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងក្រុមហ៊ុនឯកជន។

## មាតិកា


- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "គោលនយោបាយអភិវឌ្ឍ បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨" ទំព័រទី១
- វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីនៃ ន.ប.ធ. និង ន.ម.ក. ស្តីពី "នីតិវិធី និងគន្លឹះសំខាន់ៗ ដើម្បីដាក់ពាក្យស្នើសុំអាហារូបករណ៍ Manaaki New Zealand Scholarships (MNZS)" ទំព័រទី២
- កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់គុណវុឌ្ឍិវិជ្ជាជីវៈមន្ត្រីជំនាញហិរញ្ញវត្ថុសាធារណៈ ទំព័រទី២
- កិច្ចប្រជុំលើកទី១ (Kick-off) នៃក្រុមការងារស្ថិរភាពហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី៣
- កម្មវិធីការងារសង្គម- បរិស្ថាន (TR's ESG Initiative) ទំព័រទី៣
- សិក្ខាសាលាស្តីពី "ការរៀបចំលទ្ធផលគន្លឹះ និងថវិកាឆ្នាំ២០២៤ ទំព័រទី៤
- សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងប្រកាសស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" ទំព័រទី៤
- សិក្ខាសាលាស្តីពី "ការបញ្ជ្រាបការយល់ដឹងអំពីច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ" ទំព័រទី៥
- ប្រជុំជាមួយទីប្រឹក្សាបច្ចេកទេសរបស់ការិយាល័យម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO) និងតំណាងមកពីអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី៥
- កិច្ចប្រជុំស្តីពី "ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម៩ខែដើមឆ្នាំ២០២៣ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៤" ទំព័រទី៦
- ប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកសម្របសម្រួលការអនុវត្តគម្រោង ACSEP ទំព័រទី៦
- កិច្ចប្រជុំលើការងារពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុដំណាក់កាលទី១ (Wrap-up) ទំព័រទី៧
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី " វិធានការគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ " ទំព័រទី៧
- សិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពី "ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសសម្រាប់គម្រោង/កម្មវិធីក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍" ទំព័រទី៨
- កិច្ចប្រជុំពិភាក្សាការងារស្តីពី "ត្រៀមសម្រាប់វេទិការាជរដ្ឋាភិបាលផ្នែកឯកជនលើកទី១៩ ក្នុងក្រុមខណ្ឌការងារ ផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ" ទំព័រទី៩
- សិក្ខាសាលាស្តីពី "ទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" សេវាហិរញ្ញវត្ថុមិនមែនធនាគារ" ទំព័រទី៩
- ប្រជុំពិភាក្សាការងារជាមួយក្រុមប្រតិភូក្រុមហ៊ុន Shenzhen Qianhai One Internet Technology Investment Co., Ltd. និងក្រុមហ៊ុន Gold House Capital Co. Ltd ទំព័រទី១០
- កិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF Article IV) ទំព័រទី១០
- កិច្ចប្រជុំពិគ្រោះយោបល់ពីទម្រង់ផែនការអាជីវកម្មសម្រាប់ប្រើប្រាស់នៅក្នុងគម្រោង ACSEP-PIU1 វឌ្ឍនភាពប្រចាំត្រីមាសទី១ និងទី២ ឆ្នាំ២០២៣ ទំព័រទី១១
- កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "ការផ្ទេរ និងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច" ទំព័រទី១១
- ប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន TrustQuay ដើម្បីពិនិត្យលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ ទំព័រទី១២
- សិក្ខាសាលាបញ្ជ្រាបការយល់ដឹងលើការដាក់ឱ្យប្រើប្រាស់មុខងារថ្មី "មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (Asset Management)" ទំព័រទី១២
- សិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងការចែករំលែកបទពិសោធន៍ស្តីពី ការបើកផ្តល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈដោយបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈ ទំព័រទី១៣
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិធានការដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ" ទំព័រទី១៣




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨"។

## វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីនៃ ន.ប.ធ. និង ន.ម.ភ. ស្តីពី "នីតិវិធី និងគន្លឹះសំខាន់ៗ ដើម្បីដាក់ពាក្យស្នើសុំអាហារូបករណ៍ Manaaki New Zealand Scholarships (MNZS)"

នារសៀលថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), និយ័តករមូលបត្រកម្ពុជា (**ន.ម.ភ.**) និងអាហារូបករណ៍ ម៉ាណាគី ណូវែលហ្សេឡង់ បានសហការរៀបចំវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីនៃ **ន.ប.ធ.** និង **ន.ម.ភ.** ស្តីពី "នីតិវិធី និងគន្លឹះសំខាន់ៗ ដើម្បីដាក់ពាក្យស្នើសុំអាហារូបករណ៍ Manaaki New Zealand Scholarships (MNZS)" ដោយមានការគាំទ្រពីក្រុមហ៊ុន អាយឌីភី អេឌ្យូខេសិន (ខេមបូឌា) លីមីធីត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ **ន.ម.ភ.**, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **លោក Ashley Irving** នាយកសាលានៃមជ្ឈមណ្ឌល ACE។

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីចែករំលែកព័ត៌មានលម្អិត និងបទពិសោធន៍អំពីការដាក់ពាក្យស្នើសុំអាហារូបករណ៍ ដើម្បីបន្តការសិក្សាថ្នាក់អនុបណ្ឌិត និងបណ្ឌិតនៅប្រទេសណូវែលហ្សេឡង់, ការរៀបចំឯកសារសម្រាប់ដំណើរការសិក្សានៅសាកលវិទ្យាល័យនៅប្រទេសណូវែលហ្សេឡង់, ព័ត៌មានសម្រាប់ការធ្វើតេស្ត IELTS និងគន្លឹះសំខាន់ៗសម្រាប់មន្ត្រីនៃ **ន.ប.ធ.** និង **ន.ម.ភ.** ក្នុងការត្រៀមខ្លួនដាក់ពាក្យស្នើសុំអាហារូបករណ៍ MNZS។

វគ្គបណ្តុះបណ្តាលខាងលើនេះ មានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** និង **ន.ម.ភ.** សរុបចំនួន ១១៧ រូប ព្រមទាំងមានការចូលរួមពីវាគ្មិនកិត្តិយសមកពី ក្រុមហ៊ុន អាយ ឌី ភី អេឌ្យូខេសិន (ខេមបូឌា) លីមីធីត និងអតីតនិស្សិត ដែលទទួលបានអាហារូបករណ៍ MNZSផងដែរ។



រូបភាព៖ វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីនៃ **ន.ប.ធ.** និង **ន.ម.ភ.** ស្តីពី "នីតិវិធី និងគន្លឹះសំខាន់ៗ ដើម្បីដាក់ពាក្យស្នើសុំអាហារូបករណ៍ Manaaki New Zealand Scholarships (MNZS)"។

## កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់គុណវុឌ្ឍិវិជ្ជាជីវៈមន្ត្រីជំនាញហិរញ្ញវត្ថុសាធារណៈ

នារសៀលថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុន វិសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ អមដោយមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់គុណវុឌ្ឍិវិជ្ជាជីវៈមន្ត្រីជំនាញហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ម៉ាន សាហ៊ីម** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) នៅទីស្តីការ កសហវ។ កិច្ចប្រជុំនេះ មានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអគ្គនាយកដ្ឋានក្រោមឱវាទ **កសហវ** និងតំណាងស្ថាប័នក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។



រូបភាព៖ កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់គុណវុឌ្ឍិវិជ្ជាជីវៈមន្ត្រីជំនាញហិរញ្ញវត្ថុសាធារណៈ។

## កិច្ចប្រជុំលើកទី១ (Kick-off) នៃក្រុមការងារស្ថិរភាពហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នារសៀលថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី១ (Kick-off) នៃក្រុមការងារស្ថិរភាពហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.**។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ឯកឧត្តមអគ្គនាយកនិយ័តករក្រោមឱវាទ **អ.ស.ហ.** ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិក-សមាជិកា នៃក្រុមការងារស្ថិរភាពហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។



រូបភាព៖ កិច្ចប្រជុំលើកទី១ (Kick-off) នៃក្រុមការងារស្ថិរភាពហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## កម្មវិធីការងារសង្គម-បរិស្ថាន (TR's ESG Initiative)

ក្រោមគំនិតផ្តួចផ្តើម "ផ្តល់ត្រលប់ទៅវិញ និងរួមចំណែកសម្រាប់សហគមន៍ (Give Back to the Community and Pay Forward)" ដល់សង្គមនិងបរិស្ថាននៅកម្ពុជា, នាថ្ងៃសុក្រ ៧រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** រួមដំណើរដោយ **លោក យុន វាសនា, លោក ប៉ូ សំអាង, កញ្ញា ឈាន សុខារី, លោក ហាយ សុវណ្ណា** ដែលជាថ្នាក់ដឹកនាំនាយកដ្ឋាន និងសហការីនៃ **ន.ប.ធ.** បានរៀបចំកម្មវិធីការងារសង្គម-បរិស្ថាន (TR's ESG Initiative) នៅទីតាំងសាលាដូង កំពូលភ្នំគីរីរម្យ ដោយបានពាំនាំនូវអំណោយសប្បុរសធម៌រួមមាន៖ អង្ករ, ប្រេងឆា, ទឹកស៊ីអ៊ីវ, ទឹកត្រី, ត្រីខ, ត្រីងៀត, ពងទាប្រៃ, ស្ករស, អំបិល, សម្ភារៈនិងថ្នាំពេទ្យ, និងសម្ភារៈសិក្សាប្រើប្រាស់មួយចំនួនទៀត ជាដើម ព្រមទាំងបានផ្តល់សេចក្តីស្រលាញ់, សេចក្តីសង្ឃឹម, ការយកចិត្តទុកដាក់, ការចែករំលែកនូវបទពិសោធន៍ជីវិត និងការងារ ក៏ដូចជាផ្តល់កម្លាំងចិត្តដល់កុមារនៅក្នុងសាលាដើម្បីក្លាយជាទំពាំងស្នងឫស្សីដ៏រឹងមាំរបស់សង្គមនៅថ្ងៃអនាគត។ កម្មវិធីនេះ មានការចូលរួមគាំទ្រផងដែរពីក្រុមហ៊ុន កាណា ត្រាស ឯ.ក, ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី, ធនាគារ អេស៊ីលីដា ភីអិលស៊ី, ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក, ធនាគារ ស្ថាបនា ភីអិលស៊ី និងក្រុមបរធនបាល។



រូបភាព៖ កម្មវិធីការងារសង្គម-បរិស្ថាន (TR's ESG Initiative)។

## សិក្ខាសាលាស្ដីពីការរៀបចំលទ្ធផលគន្លឹះ និងថវិកាឆ្នាំ ២០២៤

នាព្រឹកថ្ងៃច័ន្ទ ១០រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាស្ដីពី "ការរៀបចំលទ្ធផលគន្លឹះ និងថវិកាឆ្នាំ ២០២៤ ដើម្បីរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" នៅសណ្ឋាគារ សុខា ភ្នំពេញ ក្រោមការដឹកនាំដោយ **ឯកឧត្តម យ៉េត ទីណែល** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**), តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃ កសហវ និងជាអគ្គលេខាធិការ **អ.គ.ហ.**។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមដោយផ្ទាល់ពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ។



***រូបភាព៖*** សិក្ខាសាលាស្ដីពី "ការរៀបចំលទ្ធផលគន្លឹះ និងថវិកាឆ្នាំ២០២៤។

## សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្ដីព្រាងប្រកាសស្ដីពី "កាតព្វកិច្ចផ្ដល់របាយការណ៍ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល"

នាព្រឹកថ្ងៃអង្គារ ១១ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ នៅអាគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្ដីព្រាងប្រកាសស្ដីពី "កាតព្វកិច្ចផ្ដល់របាយការណ៍ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** ក្នុងគោលបំណងទទួលបានមតិយោបល់ ក៏ដូចជាធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធជាពិសេសអ្នកអនុវត្តការងារផ្ទាល់ ដើម្បីឱ្យសេចក្ដីព្រាងប្រកាសខាងលើកាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុង-ជ្រោយ សំដៅដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទំនុកចិត្តពីអ្នកចូលរួមនៅក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈនេះមានការអញ្ជើញចូលរួមពីតំណាងក្រសួងយុត្តិធម៌ ធនាគារជាតិនៃកម្ពុជា និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមានការចូលរួមពីតំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្ដល់សេវាសុវត្ថិភាពឬរក្សាទុក បរធនបាលរូបវន្តបុគ្គលឯករាជ្យ និងក្រុមហ៊ុនពាក់ព័ន្ធដទៃទៀត។



***រូបភាព៖*** សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្ដីព្រាងប្រកាសស្ដីពី "កាតព្វកិច្ចផ្ដល់របាយការណ៍ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល"។

## សិក្ខាសាលាស្តីពី "ការបញ្ជ្រាបការយល់ដឹងអំពីច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ"

នៅថ្ងៃព្រហស្បត្តិ៍ ១៣រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងមន្ត្រីជំនាញ បានចូលរួមសិក្ខាសាលាស្តីពី "ការបញ្ជ្រាបការយល់ដឹងអំពីច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ" នៅទីស្នាក់ការរបស់អង្គភាពប្រឆាំងអំពើពុករលួយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ និងមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីមកពីនិយ័តករនិងអង្គភាពក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងនិស្សិតកម្មសិក្សានៃមន្ត្រីជាន់ខ្ពស់នៃសាលាភូមិន្ទរដ្ឋបាល ដែលមានសិក្ខាកាមសរុបចំនួន ៦៤ នាក់។



**រូបភាព៖** សិក្ខាសាលាស្តីពី "ការបញ្ជ្រាបការយល់ដឹងអំពីច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ"។

## ប្រជុំជាមួយទីប្រឹក្សាបច្ចេកទេសរបស់ការិយាល័យម៉ាក្រូ-សេដ្ឋកិច្ចអាស៊ានបូក៣ (AMRO) និងតំណាងមកពីអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នារសៀលថ្ងៃអង្គារ ៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានទទួលជួបប្រជុំជាមួយទីប្រឹក្សាបច្ចេកទេសរបស់ការិយាល័យម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO) ក្រោមកិច្ចសម្របសម្រួលដោយ **លោកបណ្ឌិត សោម ផៃ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិគ្រោះយោបល់ដោយផ្តោតជាចម្បងលើ៖ ការបន្ស៊ីសូចនាករភាពរឹងមាំហិរញ្ញវត្ថុអន្តរជាតិជាមួយនឹងបរិបទជាក់ស្តែងនៃវិស័យបរធនបាលកិច្ច, ការបន្តប្រមូលសូចនាករហានិភ័យសំខាន់ៗ (KRI) និងតម្រូវការទិន្នន័យដោយផ្អែកលើទម្រង់ទិន្នន័យថ្មី ក្នុងគោលដៅដើម្បីជាធាតុចូលសម្រាប់ការរៀបចំ "របាយការណ៍ស្ថិរភាពហិរញ្ញវត្ថុដំណាក់កាលទី១" ក្រោមជំនួយបច្ចេកទេសរបស់ AMRO។



**រូបភាព៖** ប្រជុំជាមួយទីប្រឹក្សាបច្ចេកទេសរបស់ការិយាល័យម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO) និងតំណាងមកពីអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## កិច្ចប្រជុំស្តីពី "ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម៩ខែដើមឆ្នាំ២០២៣ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៤

នាព្រឹកថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានចូលរួមកិច្ចប្រជុំស្តីពី "ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម៩ខែដើមឆ្នាំ២០២៣ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៤ ជូនក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកា" ដែលដឹកនាំដោយ **ឯកឧត្តម ឈឹម សារ៉េត** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



**រូបភាព៖** កិច្ចប្រជុំស្តីពី "ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម៩ខែដើមឆ្នាំ២០២៣ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៤។

## ប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកសម្របសម្រួលការអនុវត្តគម្រោង ACSEP

កាលពីថ្ងៃអង្គារ ៣កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU 1) **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការនៃ **ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការ នៃគម្រោង ACSEP-PIU 1, **លោក ណង សេរីវុធ** អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ នៃ **ន.ប.ធ.** និងជាមន្ត្រីឥណទានគម្រោង ACSEP-PIU 1, **លោក ផែម លាបហេង** ប្រធានការិយាល័យអធិការកិច្ច និងជាមន្ត្រីឥណទានគម្រោង ACSEP/PIU 1, **លោក Rene Frechet** ប្រធានក្រុមទីប្រឹក្សាគម្រោង ACSEP-PIU1, **លោកស្រី Marry Miller** ទីប្រឹក្សាអន្តរជាតិផ្នែកធានាឥណទាន, និង **លោក សួន សុភា** ទីប្រឹក្សាគ្រប់គ្រងហានិភ័យឥណទាន បានជួបប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកសម្របសម្រួលការអនុវត្តគម្រោង ACSEP នៃធនាគារស្ថាបនា (SPNB) និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) ក្នុងគោលបំណងដើម្បីចែករំលែកពីវឌ្ឍនភាពការងារ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងប្រតិបត្តិការផ្នែកឥណទាននៃគម្រោង។ កិច្ចប្រជុំនេះត្រូវបានប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាលនៃ SPNB និង ARDB។



**រូបភាព៖** ប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកសម្របសម្រួលការអនុវត្តគម្រោង ACSEP ។

## កិច្ចប្រជុំលើការងារពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុដំណាក់កាលទី១ (Wrap-up)

នារសៀលថ្ងៃព្រហស្បតិ៍ ៥កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំលើការងារពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុដំណាក់កាលទី១ (Wrap-up) ក្រោមជំនួបរវាងទីប្រឹក្សាបច្ចេកទេសក្រោមក្របខណ្ឌជំនួយបច្ចេកទេសរបស់ការិយាល័យម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.**។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ឯកឧត្តមអគ្គនាយកនិយ័តករក្រោមឱវាទ **អ.ស.ហ.** ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិក-សមាជិកា នៃក្រុមការងារស្ថិរភាពហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។




**រូបភាព៖** កិច្ចប្រជុំលើការងារពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុដំណាក់កាលទី១ (Wrap-up)។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិធានការគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ "

នាព្រឹកថ្ងៃសុក្រ ៦កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិធានការគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលប្រព្រឹត្តទៅ នៅសណ្ឋាគារ រ៉ហ្វហ្វលស៍ ឡឺ រ៉ូយ៉ាល់។ សិក្ខាសាលាផ្សព្វផ្សាយនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ច្រាប និងលើកកម្ពស់ការយល់ដឹងស្តីពីបច្ចេកវិទ្យាហិរញ្ញវត្ថុដល់ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន។ កម្មវិធីនេះមានការអញ្ជើញចូលរួមដោយ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ឯកឧត្តមអគ្គនាយកនិយ័តករក្រោមឱវាទ **អ.ស.ហ.** ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលអញ្ជើញមកពីស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន។




**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិធានការគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"។

## សិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពី "ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសសម្រាប់គម្រោង/កម្មវិធី ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍"

នាព្រឹកថ្ងៃសុក្រ ៦កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP/PIU1), **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងជាប្រធានផ្នែកលទ្ធកម្មនៃគម្រោង ACSEP/PIU1 បានដឹកនាំក្រុមមន្ត្រីបច្ចេកទេស និងទីប្រឹក្សាគម្រោង ACSEP/PIU1 ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពី "ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសសម្រាប់គម្រោង/កម្មវិធី ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍" ដែលបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅសណ្ឋាគារ សុខា ភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ប៉ែន ធីរុង្គ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សិក្ខាសាលានេះ បានរៀបចំឡើងក្នុងគោលបំណងដើម្បីរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស សម្រាប់គម្រោង/កម្មវិធីក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ឱ្យមានសង្គតិភាព និងបានពេញលេញត្រឹមត្រូវ ស្របតាមគំរូរបាយការណ៍។

សិក្ខាសាលាខាងលើ មានការចូលរួមដោយក្រុមការងារគម្រោង ACSEP/PIU1, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ព្រមទាំងក្រសួង-ស្ថាប័នផ្សេងទៀត ក៏ដូចជាអង្គភាពគ្រប់គ្រង និងអនុវត្តគម្រោងពាក់ព័ន្ធផ្សេងៗទៀត។







**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពី "ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសសម្រាប់គម្រោង/កម្មវិធី ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សាការងារស្តីពី "ត្រៀមសម្រាប់វេទិការាជរដ្ឋាភិបាលផ្នែកឯកជនលើកទី១៩ ក្នុងក្រុមខណ្ឌការងារ ផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ"

នារសៀលថ្ងៃសុក្រ ៦កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារក្នុងក្របខណ្ឌក្រុមការងារទី១៤/ឈ ផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីត្រៀមសម្រាប់ "វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩" នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។ កិច្ចប្រជុំនេះ មានការចូលរួមពីនិយ័តករក្រោមឱវាទនៃ **អ.ស.ហ.** និងតំណាងសមាគមធុរកិច្ចមកពីវិស័យឯកជន ក្នុងក្របខណ្ឌសេវាកម្មហិរញ្ញវត្ថុមិនមែនធនាគារ។




**រូបភាព៖** កិច្ចប្រជុំពិភាក្សាការងារស្តីពី "ត្រៀមសម្រាប់វេទិការាជរដ្ឋាភិបាលផ្នែកឯកជនលើកទី១៩ ក្នុងក្រុមខណ្ឌការងារ ផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ"។

## សិក្ខាសាលាស្តីពី "ទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" សេវាហិរញ្ញវត្ថុមិនមែនធនាគារ"

នាព្រឹកថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកសិក្ខាសាលាស្តីពី "ទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ**) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។

សិក្ខាសាលាផ្សព្វផ្សាយនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រមូលធាតុចូលពីគ្រប់តួអង្គពាក់ព័ន្ធទាំងក្រសួង-ស្ថាប័នសាធារណៈទាំងស្ថាប័នអន្តរជាតិសំខាន់ៗ និងវិស័យឯកជន សម្រាប់ការរៀបចំវិធានការគោលនយោបាយខាងលើនេះ។

កម្មវិធីសិក្ខាសាលានេះមានការអញ្ជើញចូលរួមដោយឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ឯកឧត្តមអគ្គនាយកនៃនិយ័តករក្រោមឱវាទ **អ.ស.ហ.** ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលអញ្ជើញមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន។




**រូបភាព៖** សិក្ខាសាលាស្តីពី "ទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" សេវាហិរញ្ញវត្ថុមិនមែនធនាគារ"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ប្រជុំពិភាក្សាការងារជាមួយក្រុមប្រតិភូក្រុមហ៊ុន Shenzhen Qianhai One Internet Technology Investment Co., Ltd. និងក្រុមហ៊ុន Gold House Capital Co. Ltd

នាព្រឹកថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានទទួលជួបប្រជុំពិភាក្សាការងារជាមួយក្រុមប្រតិភូ ដែលអញ្ជើញមកពីក្រុមហ៊ុន Shenzhen Qianhai One Internet Technology Investment Co., Ltd. ជាក្រុមហ៊ុនមានជំនាញខ្ពស់លើបច្ចេកវិទ្យាប្រព័ន្ធទូរសព្ទនិងប្រព័ន្ធ WIFI និងជាប្រតិបត្តិករ WIFI ផ្តល់សេវាឱ្យមន្ទីពេទ្យឈានមុខគេរបស់ប្រទេសចិនចំពោះប្រព័ន្ធសុខាភិបាល និងក្រុមហ៊ុន Gold House Capital Co. Ltd ដែលជាក្រុមហ៊ុនគ្រប់គ្រងការវិនិយោគប្រកបដោយវិជ្ជាជីវៈនៃប្រទេសចិន ដោយមានការសម្របសម្រួលពីក្រុមហ៊ុន ហ្វ្រេន កាថេ អ៊ិនវេសមិុន ត្រាស (ខេមបូឌា) ម.ក ដើម្បីពិភាក្សាអំពីកាលានុវត្តភាពសម្រាប់ការវិនិយោគនៅកម្ពុជា និងស្វែងយល់អំពីការអភិវឌ្ឍទីផ្សារបរធនបាលកិច្ច ក៏ដូចជាគំនិតផ្តួចផ្តើមនានា ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និងទីផ្សារបរធនបាលកិច្ចនៅកម្ពុជា នាពេលខាងមុខផងដែរ។



**រូបភាព៖** ប្រជុំពិភាក្សាការងារជាមួយក្រុមប្រតិភូក្រុមហ៊ុន Shenzhen Qianhai One Internet Technology Investment Co., Ltd. និងក្រុមហ៊ុន Gold House Capital Co. Ltd។

## កិច្ចប្រជុំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF Article IV)

នារសៀលថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ហាយ សុវណ្ណា** ប្រធានស្ដីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និង **លោក ណង សេរីវុធ** អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការ បានចូលរួមកិច្ចប្រជុំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF Article IV) លើវឌ្ឍនភាពគោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ និងស្ថិរភាពហិរញ្ញវត្ថុ ក្រោមការសម្របសម្រួលរបស់ **លោកបណ្ឌិត សោម ផៃ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និងដោយមានការចូលរួមពីតំណាងនិយ័តករពាក់ព័ន្ធក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។



**រូបភាព៖** កិច្ចប្រជុំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF Article IV)។

## កិច្ចប្រជុំពិគ្រោះយោបល់ពីទម្រង់ផែនការអាជីវកម្មសម្រាប់ប្រើប្រាស់នៅក្នុងគម្រោង ACSEP-PIU1

កាលពីថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU 1) **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ នៃ **ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការ នៃគម្រោង ACSEP-PIU 1 បានដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ពីទម្រង់ផែនការអាជីវកម្មសម្រាប់ប្រើប្រាស់នៅក្នុងគម្រោង ACSEP-PIU1។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយ លោក-លោកស្រី ដែលជាសមាជិក-សមាជិកានៃអង្គភាពអនុវត្តគម្រោង ACSEP-PIU1 និងក្រុមទីប្រឹក្សាគម្រោង ACSEP-PIU1, តំណាងមកពីអង្គភាពអនុវត្តគម្រោង ACSEP-MAFF PMU/PIU2, តំណាងមកពីធនាគារស្ថាបនា (SPNB) និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)។





**រូបភាព៖** កិច្ចប្រជុំពិគ្រោះយោបល់ពីទម្រង់ផែនការអាជីវកម្មសម្រាប់ប្រើប្រាស់នៅក្នុងគម្រោង ACSEP-PIU1។

## កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "ការផ្ទេរ និងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច"

នាព្រឹកថ្ងៃអង្គារ ១០កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ**២០២៣ ឯកឧត្តម នន ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាកម្រិតនាយកដ្ឋានលើសេចក្តីព្រាងប្រកាសស្តីពី "ការផ្ទេរ និងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច" ដោយមានការចូលរួមពី **កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច អមដោយមន្ត្រីជំនាញនៃនាយកដ្ឋាន។



**រូបភាព៖** កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "ការផ្ទេរ និងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន TrustQuay ដើម្បីពិនិត្យលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ

កាលពីថ្ងៃពុធ ១១កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីបានអញ្ជើញទទួលជួបប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន TrustQuay តំណាងដោយ **លោក លោក** Ryan Pang ប្រធានផ្នែកអភិវឌ្ឍន៍ធុរកិច្ច នៃក្រុមហ៊ុន TrustQuay និងសហការី ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) និងក្រុមហ៊ុន TrustQuay ក្នុងគោលដៅដើម្បីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ចស្របតាមឧត្តមានុវត្តន៍អន្តរជាតិនៃប្រតិបត្តិការបរធនបាលកិច្ចដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។



*រូបភាព៖* ប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន TrustQuay ដើម្បីពិនិត្យលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ ។

## សិក្ខាសាលាបញ្ជ្រាបការយល់ដឹងលើការដាក់ឱ្យប្រើប្រាស់មុខងារថ្មី "មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (Asset Management)"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១២ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ អមដោយសហការី បានចូលរួមសិក្ខាសាលាបញ្ជ្រាបការយល់ដឹងលើការដាក់ឱ្យប្រើប្រាស់មុខងារថ្មី "មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (Asset Management)" ក្នុង FMIS ដើម្បីបញ្ជ្រាបការយល់ដឹងពីការត្រៀមប្រើប្រាស់នូវមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុង FMIS នៅឆ្នាំ២០២៤ ខាងមុខនេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS និង មានការចូលរួមពីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋក្រោមឱវាទក្រសួងចំនួន ៥ រួមមាន៖ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមប្រព័ន្ធអនឡាញ Zoom។




*រូបភាព៖* សិក្ខាសាលាបញ្ជ្រាបការយល់ដឹងលើការដាក់ឱ្យប្រើប្រាស់មុខងារថ្មី "មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (Asset Management)"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## សិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងការចែករំលែកបទពិសោធន៍ស្ដីពី ការបើកផ្ដល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈដោយបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈ

នាព្រឹកថ្ងៃចន្ទ ១រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ អមដោយសហការី បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងការចែករំលែកបទពិសោធន៍ស្ដីពី ការបើកផ្ដល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈដោយបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈ ដឹកនាំដោយ **ឯកឧត្តម ប៊ូ វឌ្ឍសុខា** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**), តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.គ.ហ.**។ សិក្ខាសាលានេះ មានការអញ្ជើញចូលរួមដោយផ្ទាល់ពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅសណ្ឋាគារសុខាភ្នំពេញ។



*រូបភាព៖* សិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងការចែករំលែកបទពិសោធន៍ស្ដីពី ការបើកផ្ដល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈដោយបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈ។

## សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "វិធានការដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ"

នាព្រឹកថ្ងៃអង្គារ ២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក ហាយ សុវណ្ណា** ប្រធានស្ដីទីនៃនាយកដ្ឋានចុះបានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "វិធានការដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ" នៅសណ្ឋាគារ Sea Breeze Hotel & Villa ខេត្តព្រះសីហនុ។ គោលបំណងនៃការរៀបចំសិក្ខាសាលាផ្សព្វផ្សាយនេះ គឺដើម្បីជំរុញការអនុវត្តវិធានការរាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ចេញវិធានការជាកញ្ចប់ ដើម្បីដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ រួមមាន ការលើកទឹកចិត្តពន្ធដារ ការសម្របសម្រួលលិខិតអនុញ្ញាតសាងសង់ និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ យន្តការបរធនបាលកិច្ច ក៏ត្រូវបានដាក់បញ្ចូលនៅក្នុងវិធានការដោះស្រាយគម្រោងវនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុនេះផងដែរ។



*រូបភាព៖* សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "វិធានការដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888